អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីអញ្ជើញចូលរួមក្នុងសវនាការរបស់អង្គបុរេជំនុំជម្រះនៃអ.វ.ត.ក

ថ្ងៃទី ២០ ខែវិច្ឆិកាឆ្នាំ២០០៧

អង្គបុរេជំនុំជម្រះ នៃអ.វ.ត.កបានកំណត់ថ្ងៃបើកសវនាការសាធារណៈនាថ្ងៃទី ២០ ខែវិច្ឆិកាឆ្នាំ២០០៧។ អង្គបុរេជំនុំជម្រះបានសំរេច និងអនុញ្ញាតិឲ្យមានការផ្សាយបន្តផ្ទាល់ពីដំណើរការសវនាការទៅដល់ស្ថានីយវិទ្យុ និងទូរទស្សន៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ។ តំណាងប្រព័ន្ធសារព័ត៌មាននីមួយៗនិងសាធារណៈជនទូទៅនឹងត្រូវបានអញ្ជើញចូលរួមដោយផ្ទាល់នៅក្នុងសវនាការនោះ ។

សវនាការនឹងចាប់ផ្តើមនាវេលាម៉ោង ១០ះ៣០ ព្រឹក នៅថ្ងៃទី ២០ ខែវិច្ឆិកា និងថ្ងៃផ្សេង បន្តបន្ទាប់ទៀតដែលកំណត់ដោយចៅក្រម។អ្នកចូលរួមទាំងអស់ត្រូវមានវត្តមាននៅកន្លែងអង្គុយដែលបំរុងទុករយៈពេល ៣០ នាទីមុនពេលសវនាការចាប់ផ្តើម។ នាថ្ងៃទី ២០ខែវិច្ឆិកា អ្នកចូលរួមទាំងអស់តំរូវឲ្យមកដល់បរិវេណអ.វ.ត.កក្នុងចន្លោះពីម៉ោង ០៨ះ៣០ ដល់ម៉ោង០៩ះ០០ព្រឹកដើម្បីទុកពេលឲ្យសន្តិសុខធ្វើការត្រួតពិនិត្យនិងចេញប័ណ្ណ។ ក្លោងទ្វាមុខនឹងបិទនៅវេលាម៉ោង០៩ះ៤៥ព្រឹក ឬនៅពេលដែលកន្លែងអង្គុយនៅក្នុងសាលសវនាការពេញអស់។

អ្នកចូលរួមទាំងអស់ត្រូវបង្ហាញអត្តសញ្ញាណសំគាល់ដែលមានភ្ជាប់រូបថត ហើយត្រូវឆ្លងកាត់ការត្រួតពិនិត្យឆែកឆេររបស់សន្តិសុខ។ សូមកត់សំគាល់ផងដែរថាបុគ្គលក្រោមអាយុ១៨ឆ្នាំនឹងមិនអនុញ្ញាតិឲ្យចូលក្នុងសាលសវនាការនោះទេ។ ទូរស័ព្ទ កាបូបធំៗ ចំណីអាហារនិង ភេសជ្ជៈនឹងត្រូវហាមឃាត់មិនអោយនាំចូលក្នុងសាលសវនាការនោះទេ។

**កន្លែងអង្គុយនៅក្នុងសាលសវនាការបានរៀបចំដូចខាងក្រោមនេះ ៖**

**អ្នកសារព័ត៌មាន៖** កន្លែងអង្គុយចំនួន ១០០ បានបំរុងទុកសំរាប់តំណាងសារព័ត៌មាននានាដែលមានបំនងចង់ចូលរួម។ ពួកគេទាមទារឲ្យមានការចុះឈ្មោះជាមុន។ កាលបរិច្ឆេទផុតកំនត់សំរាប់ការចុះឈ្មោះគឺនាថ្ងៃព្រហស្បត៍ទី១៥ ខែវិច្ឆិកាវេលាម៉ោង១៧ះ០០។ ក្នុងករណីចំនួននៃកន្លែងអង្គុយនេះនៅទំនេរមុនម៉ោង ១០ះ០០ព្រឹក នៅថ្ងៃសវនាការ កន្លែងទាំងនោះនឹងរៀបចំសំរាប់សាធារណៈជនទូទៅ។

សំរាប់ព័ត៌មានបន្ថែមនិងការសំរបសំរួលផ្សេងៗសូមមើលក្នុងសេចក្តីប្រកាសព័ត៌មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយឬទាក់

ទងលោករាជ សម្បត្តិ តាមរយៈទូរស័ព្ទលេខ ០១២ ៨៨៨ ១៥៦ ឬលោក ភីធើ ហ្វូស្ទ័រ តាមរយៈទូរស័ព្ទលេខ ០១២៤៨៨ ៤២១។

**អង្គការក្រៅរដ្ឋាភិបាល៖** កន្លែងអង្គុយចំនួន ៥០បានបំរុងទុក សំរាប់ទាំងអង្គការជាតិនិងអន្តរជាតិ(អង្គការនីមួយៗអាចមានសិទ្ធិទទួលកន្លែងអង្គុយចំនួន២ ) និងទាមទារឲ្យមានការចុះឈ្មោះជាមុន។ កាលបរិច្ឆេទផុតកំនត់សំរាប់ការចុះឈ្មោះគឺនាថ្ងៃព្រហស្បត៍ ទី១៥ខែវិច្ឆិកាវេលាម៉ោង១៧ះ០០។ក្នុងករណីកន្លែងអង្គុយទាំងនោះនៅសល់មុនម៉ោង ១០ព្រឹក នៅថ្ងៃសវនាការ កន្លែងអង្គុយទាំងនោះនឹងអោយរៀបចំជូនសំរាប់សាធារណៈជនទូទៅ។

**ក្រុមផ្សេងៗ៖** កន្លែងអង្គុយចំនួន ១៤០បំរុងទុកសំរាប់ក្រុមផ្សេងៗ (កន្លែងអង្គុយចំនួន ២០ សំរាប់មួយក្រុមនិមួយៗ)។ កាលបរិច្ឆេទផុតកំនត់សំរាប់ការចុះឈ្មោះគឺនាថ្ងៃព្រហស្បត៍ ទី១៥ខែវិច្ឆិកាវេលាម៉ោង១៧ះ០០។ ក្នុងករណីកន្លែងអង្គុយសំរាប់ក្រុមផ្សេងៗនៅទំនេរមុនម៉ោង  ១០ព្រឹក នៅថ្ងៃសវនាការ កន្លែងអង្គុយទាំងនោះនឹងអោយរៀបចំជូនសំរាប់សាធារណៈជនទូទៅ។

**សាធារណៈជនទូទៅ៖**

សាធារណៈជនទូទៅត្រូវបានលើកទឹកចិត្តក្នុងការចុះឈ្មោះជាមុនហើយអ្នកដែលមកមុននឹងទទួលបានកន្លែងអង្គុយមុន។ កន្លែងអង្គុយសំរាប់សាធារណៈជនមានបំរុងទុកចំនួន ១០០ កន្លែង។ ក្នុងករណីលោកអ្នកត្រូវការធ្វើដំណើរតាមរថយន្តក្រុងរបស់អ.វ.ត.ក ដោយឥតគិតថ្លៃ គឺលោកអ្នកត្រូវធ្វើការចុះឈ្មោះជាមុន។

**មធ្យោបាយធ្វើដំណើរ** ៖ អ.វ.ត.ក នឹងផ្តល់សេវាកម្មធ្វើដំណើរដោយឥតគិតថ្លៃសំរាប់អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជនដែលមិនមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនទាំងទៅនិងមកកាន់ អ.វ.ត.ក។ រថយន្តក្រុងនឹងចាកចេញពីមុខស្ថានីយរាជាយស្ម័យានពីចន្លោះម៉ោង ០៧ះ៣០ ដល់ម៉ោង០៨ះ០០ នៅរាល់ថ្ងៃសវនាការ។ សំរាប់អ្នកត្រូវការសេវាកម្មនេះគឺទាមទារឲ្យមានការចុះឈ្មោះជាមុន។

អ.វ.ត.ក មានទីតាំងស្ថិតនៅសង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ៤ចំងាយប្រមាណ១៦គីឡូម៉ែត្រពីវត្តភ្នំ។សាធារណៈជន
និងតំណាងសារព័ត៌មាននានាសូមអញ្ជើញចូលតាមច្រកទ្វាសំរាប់អ្នក
ចូលទស្សនាដែលស្ថិតនៅប៉ែកខាងកើតនៃបរិវេណអ.វ.ត.ក។

**ការសំរបសំរួលទូទៅ** ៖ ទឹកបរិសុទ្ធមានដាក់នៅផ្លូវចូលនៅខាងក្រៅសាលសវនាការ។ ភេសជ្ជៈនិងអាហារហាម នាំចូលក្នុងសាលសវនាការ។ កញ្ចប់បាយឬអាហារថ្ងៃត្រង់អាចទិញបាននៅទីនេះ។ បង្គន់អនាម័យមាននៅក្នុង អាគារសវនាការនិងចំណតរថយន្ត។

ចំណតរថយន្តមានបំរុងទុកសំរាប់អ្នកចូលរួមដែលប្រើមធ្យោបាយផ្ទាល់ខ្លួនរាប់ទាំងរថយន្តក្រុងនិង រថយន្តតូច។ ជំនួយសំរាប់ជនពិការក៏មានផ្តល់ជូនផងដែររាប់បញ្ចូលទាំងកន្លែងអង្គុយរុញ។

ការចុះឈ្មោះសំរាប់សាធារណៈជនទូទៅនិងសេវាកម្មធ្វើដំណើរសូមទាក់ទងមកកាន់

លោកជីន ហេមវិចិត្រ

ទូរសព្ទ: (០២៣)២១៩៨១៤ លេខបន្ត:៦០៦៥

ទូរសព្ទដៃ: (០១២) ៦៩៦ ២២០

ទូរសារ: 855 (0)23 ២១៩៨៤១ លេខបន្ត:៦០៦៩

អ៊ីម៉ែល: info@eccc.gov.kh